

# បិសាចអោយឆ្មាខ្ញុំមកវិញ!


Gin Teguh

Naafi Nur Rohma



Let's Read

The Asia Foundation



ដល់ពេលវេលាដែល បឺណូ ត្រូវឱ្យចំណីឆ្មារបស់គាត់ ។ ប៉ុន្តែ ឯណា ផុស? បឺណូ មិនបានឃើញផុសតាំងពីព្រលឹមមកម្ល៉េះ។ ផុស ផុស?



នេះនែ នៅទីនេះសោះ! តើឯងកំពុងធ្វើអ្វី?




"ផុស មកនេះមក!"




ទេ!!! បិសាចចាប់ ផុស ទៅហើយ!



”ហេ! បិសាច! កុំយកឆ្មារបស់យើងទៅ!”



”ឯងគិតថាយើងខ្លាចឯងឬ? យើងអាចរត់លឿនជាងឯងទៀត!” បីណូស្រែក។



ហេតុអីបានជាបិសាចធំទៅៗយ៉ាងនេះ?



”ហេតុអ្វីបានជាវាធំទៅៗអ៊ីចឹង?” បីណូឆ្ងល់។



បិសាចក្រហឹម!!!



ម៉េវ! ម៉េវ! ម៉េវ!

” កុំខ្លាចអី ផុស។ ខ្ញុំនឹងជួយឯងឱ្យបាន”បឺណូព្យាយាមរត់តាម។



# អូយ!



"អូ! តាមពិតសំរាមធ្វើឲ្យបិសាចនេះធំឡើងៗ"។



ពេលនេះ បីណូ យល់ហើយ៖
បីណូ គួរតែសម្អាតសំរាម មុនពេលបិសាចស៊ីវា ហើយរីកធំជាងមុន!



ប្រាវ !ប្រាវ! ប៊ីណូ ចោលសំរាមទៅក្នុងធុងសំរាមយ៉ាងលឿន តាមតែគាត់អាចធ្វើបាន។



”ហាហា! គ្មានអ្វីធ្វើឱ្យឯងធំទៀតបានទេ បិសាច!” បីណូ
និយាយទាំងសប្បាយចិត្តខ្លាំង។



គម្រោងរបស់បឹណ្ឌជោគជ័យមែន បិសាចចាប់ផ្ដើមតូចបន្តិចម្ដងៗ នៅពេលដែល បឹណ្ឌ ប្រមូលសំរាមដាក់ចោលក្នុងធុងកាន់តែច្រើន។



”យេ! ឈ្នះហើយ!” បីណូស្រែកយ៉ាងធូរចិត្ត។



ឆ្មារបស់បីណូបានរួចផុតពីកណ្ដាប់ដៃបិសាចសំរាម!



"ឯងច្បាស់ជាឃ្លានខ្លាំងហើយ!" បីណូនិយាយទៅកាន់ឆ្មារបស់គាត់។



”អ៊ាំ ឯងធំក្លិនស្អុយណាស់!” បឺណូមានការងារធ្វើមួយទៀតហើយ!

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*Monster, Kembalikan Kucingku! (Monster, Give My Cat Back!)*, Author: Gin Teguh. Illustrator: Naafi Nur Rohma. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by-nc/4.0/